


# កាតព្វកិច្ចសារពើពន្ធ
# របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

TOUCH CHEAKADO

# មាតិកា

១.ទិដ្ឋភាពទូទៅ

២.កាតព្វកិច្ចសារពើពន្ធ

   ២.១ កាតព្វកិច្ចចុះបញ្ជីពន្ធដារ

   ២.២ កាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ

   ២.៣.កាលបរិច្ឆេទកំណត់បង់ពន្ធ

៣. ពន្ធកាត់ទុកទូទៅ

៤. ពន្ធលើប្រាក់បៀវត្ស

៥. កាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត


បើកប្រាក់ខែជូនមន្ត្រីរាជការ
To Pay Salary For Civil Servants
សាងសង់មន្ទីរពេទ្យ
To Build Hospitals
បើកប្រាក់ខែជូនយោធាកម្លាំងប្រដាប់អាវុធ
To Pay Salary For Soldiers And Forces
សាងសង់ផ្លូវ
To Build Roads
TAXES
សាងសង់ស្ពាន
To Build Bridges
ការពារព្រំដែន
To Defend Borders & Heritages
សាងសង់សាលារៀន
To Build Schools

# ១. ទិដ្ឋភាពទូទៅ

# ១.១. គោលបំណង និងគោលដៅ

- គោលបំណងពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- គោលដៅផ្តល់ការណែនាំបន្ថែមអំពីកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តធានាការអនុវត្តប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

# ១.២. និយមន័យ

- **សមាគម** សំដៅដល់អង្គការសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល ដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។ សមាគមរួមបញ្ចូលផងដែរនូវ សភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម។
- **ប្រភេទសមាគម៖**
  ១. **សមាគមក្នុងស្រុក៖** សំដៅដល់សមាគមដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  ២. **សមាគមបរទេស៖ សំដៅដល់**សមាគមដែលបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

# ១.២. និយមន័យ

- **អង្គការមិនមែនរដ្ឋាភិបាល៖** សំដៅដល់អង្គការមិនមែនសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល រួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គលក្រៅពីស្ថាប័នរដ្ឋាភិបាល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃចែកគ្នា។
- **ប្រភេទអង្គការមិនមែនរដ្ឋាភិបាល៖**
  1. **អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក៖** សំដៅដល់អង្គការដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  2. **អង្គការមិនមែនរដ្ឋាភិបាលបរទេស៖** សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

# ១.២. និយមន័យ

- **សកម្មភាពគោលដៅសុទ្ធសាធ៖**
  ១.**គោលដៅសុទ្ធសាធរបស់អង្គការមិនមែនរដ្ឋាភិបាល៖** សំដៅដល់សកម្មភាព ដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។
  ២.**គោលដៅសុទ្ធសាធរបស់សមាគម៖** សំដៅដល់សកម្មភាពរបស់សមាគម ដែលប្រាក់ចំណូលមិនត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល។
- **សកម្មភាពមិនស្ថិតក្នុងគោលដៅសុទ្ធសាធ** សំដៅដល់សកម្មភាពអាជីវកម្មដោយឡែករបស់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិក្រៅពីសកម្មភាពគោលដៅសុទ្ធសាធ។

# ២. កាតព្វកិច្ចសារពើពន្ធ

# ២.១. កាតព្វកិច្ចចុះបញ្ជីពន្ធដារ

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវមានកាតព្វកិច្ចចុះញ្ជីសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃ៖

១.ក្រោយពីចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច

**សកម្មភាពសេដ្ឋកិច្ច** សំដៅដល់សកម្មភាព របស់ បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមាន បំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុង គោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។



# ២.១. ភាតព្វកិច្ចចុះបញ្ជីពន្ធដារ

២.ក្រោយមានការផ្លាស់ប្តូរកម្មវត្ថុអាជីវកម្មឬ សកម្មភាពអាជីវកម្ម អាសយដ្ឋាន នាមករណ៍ សមាសភាពអ្នកគ្រប់គ្រងការបញ្ឈប់អាជីវកម្ម អ្នកទទួលបន្ទុកកិច្ចការពន្ធដារព័ត៌មានគណនី ធនាគារ ព័ត៌មានទំនាក់ទំនង (លេខទូរស័ព្ទ ឬសារអេឡិចត្រូនិក) ...។ល។



# ២.២. កាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពគោលដៅសុទ្ធសាធ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ៖

  ១.បង់ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ប្រចាំខែ

  ២.ករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទទួលបានការអនុញ្ញាតលើកលែងពន្ធលើប្រាក់ចំណូល ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម៖

  - ប្រកាសពន្ធប្រចាំខែ ដោយចូលទៅទិនានុប្បវត្តិលក់ ក្នុងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) រួចជ្រើសរើសយកពាក្យលើកលែងសម្រាប់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល
  - ប្រកាសពន្ធលើប្រាក់ចំណូល នៅក្នុងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing)ដោយជ្រើសរើសអត្រាពន្ធលើប្រាក់ចំណូល 0%

# ២.២. កាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ

៣.លិខិតប្រកាសពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធជាអាទិ៍មាន ព័ត៌មានគណនីធនាគារ របាយការណ៍ហិរញ្ញវត្ថុ កិច្ចព្រមព្រៀងហិរញ្ញប្បទាន ផែនការគម្រោងសកម្មភាព របាយការណ៍សកម្មភាពអនុវត្តគម្រោងនិងឯកសារពាក់ព័ន្ធដទៃទៀត។

- សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពមិនស្ថិតក្នុងគោលដៅសុទ្ធសាធ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ រួមមាន ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម និងពន្ធអាករដទៃទៀត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

# ២.៣. កាលបរិច្ឆេទកំណត់បង់ពន្ធ

## បង់ពន្ធប្រចាំខែ



ត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី÷






| | |
|---|---|
| នៃខែបន្ទាប់សម្រាប់ការដាក់លិខិតប្រកាសដោយផ្ទាល់ ឬថ្ងៃទី២៥ នៃខែបន្ទាប់សម្រាប់ការដាក់លិខិតប្រកាសអនឡាញ (E-Filing) | ប្រាក់រំដោះពន្ធលើប្រាក់ចំណូល, អាករបំភ្លឺសាធារណៈ, អាករពិសេសលើទំនិញនិងសេវាមួយចំនួន, អាករលើការស្នាក់នៅ, ពន្ធកាត់ទុកទូទៅ, ពន្ធលើប្រាក់បៀវត្ស, អាករលើតម្លៃបន្ថែម |

# ២.៣.កាលបរិច្ឆេទកំណត់បង់ពន្ធ (ត)

## បង់ពន្ធប្រចាំឆ្នាំ



ត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី÷



| | |
|---|---|
| ៣១ ខែមីនា នៃឆ្នាំបន្ទាប់ | ពន្ធលើប្រាក់ចំណូល |
| ៣១ ខែមីនា នៃឆ្នាំនីមួយៗ | ពន្ធប៉ាតង់ |

# ៣.ពន្ធកាត់ទុកទូទៅ

# ១. ពន្ធកាត់ទុកលើនិវាសនជន

1. អត្រា ១៥%

- ការទូទាត់ចំពោះការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែលឱ្យទៅបុគ្គលនិវាសនជនដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- សួយសារទ្រព្យអរូបី និងការទូទាត់រាល់អត្ថប្រយោជន៍ផ្សេងៗពីភាគកម្មក្នុងធនធានរ៉ែ ក្រៅពីប្រាក់ចំណូលសុទ្ធបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក
- ការប្រាក់ដែលអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលមិនមែនជាធនាគារក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ។

# ១. ពន្ធកាត់ទុកលើនិវាសនជន

2. **អត្រា ១០%** ប្រាក់ចំណូលពីការជួលចលន ឬអចលនទ្រព្យ
3. **អត្រា ៦%** ការប្រាក់ដែលធនាគារបង់ឱ្យអ្នកជាប់ពន្ធនិវាសនជនមានគណនីបញ្ញើមានកាលកំណត់
4. **អត្រា ៤%** ការប្រាក់ដែលធនាគារ បង់ឱ្យអ្នកជាប់ពន្ធនិវាសនជនមានគណនីសន្សំគ្មានកាលកំណត់ ។

# ២. ពន្ធកាត់ទុកលើអនិវាសនជន

- ការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះឱ្យអ្នកជាប់ពន្ធ អនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធ ១៤% នៃទឹកប្រាក់ត្រូវបើក។
- ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ នៅកម្ពុជា។

# ២. ប្រាក់ចំណូលប្រភពកម្ពុជា

ក- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ឬក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន ឬស្ថាប័នរបស់រដ្ឋាភិបាលកម្ពុជា។

ខ- ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន

គ- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងប្រទេសកម្ពុជា

ឃ- ប្រាក់ចំណូលពីការគ្រប់គ្រងនិងសេវាបច្ចេកទេសដែលបានទូទាត់ដោយបុគ្គលនិវាសនជន ។

# ២. ប្រាក់ចំណូលប្រភពកម្ពុជា (ត)

ង- ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យ ឬអចលនទ្រព្យ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងប្រទេសកម្ពុជា

ច- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបី ដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងកម្ពុជា

ឆ- ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងកម្ពុជា

ជ- បុព្វលាភធានារ៉ាប់រងឬ ធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងប្រទេសកម្ពុជា

# ២. ប្រាក់ចំណូលប្រភពកម្ពុជា (ត)

ឈ- ផលចំណេញពីការលក់ចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងកម្ពុជា

ញ- ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងកម្ពុជា ។

- អ្នកជាប់ពន្ធនិវាសនជននៅកម្ពុជា និងអ្នកជាប់ពន្ធអនិវាសនជនអាចមានប្រាក់ចំណូលប្រភពកម្ពុជាផ្សេងទៀតពីការប្រកបអាជីវកម្មនៅក្នុងកម្ពុជា ។

# ៣.ការលើកលែងពន្ធកាត់ទុក

ការបើកប្រាក់ឬការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ត្រូវបានអនុញ្ញាតឱ្យលើកលែងពន្ធកាត់ទុក÷

- ការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក
- ការទូទាត់ទៅឱ្យរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល នូវសួយសារ ឬប្រាក់ឈ្នួលលើចលនទ្រព្យ ឬអចលនទ្រព្យ រួមទាំងឡូត៍នៃសាទ ព្រៃគុប៏ កំពង់ដរ ភាស៊ីផ្សារ...។

# ៣.ការលើកលែងពន្ធកាត់ទុក

- ការទូទាត់ប្រាក់ចំណូលដែលជាប់ពន្ធលើប្រាក់បៀវត្ស ឬ ពន្ធលើអត្ថប្រយោជន៍បន្ថែម

- ការទូទាត់ប្រាក់ចំពោះការផ្គត់ផ្គង់សេវាតម្លៃក្រោម ៥០ ០០០ រៀល។

- ការទូទាត់ក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសចំពោះប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល និងចំពោះប្រាក់ចំណូលពីការផ្គត់ផ្គង់កញ្ចប់សូហ្វវែរ និងចំពោះប្រាក់ចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យ។

# លិខិតប្រកាសពន្ធកាត់ទុក

## I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN)

ពន្ធកាត់ទុកសរុប
Total withholding tax

## II- ពន្ធកាត់ទុក / WITHHOLDING TAX

សូមសរសេរពាក្យ «គ្មាន» ប្រសិនបើគ្មានទិន្នន័យ ឬប្រតិបត្តិការ / "NIL" for No Data or Transaction

| ល.រ No. | ពន្ធកាត់ទុកលើនិវាសនជន Withholding tax on resident (A) | ទឹកប្រាក់ត្រូវបើក Amount to be paid (B) | អត្រាពន្ធ Tax rate (C) | ពន្ធកាត់ទុក Withholding tax (D = B x C) |
|---|---|---|---|---|
| 01 | ការបំពេញសេវានានា និងសួយសារចំពោះទ្រព្យអរូបី ភាគកម្មធនធានរ៉ែ<br>Performance of Service and Royalty for intangibles, interests in minerals | | 15% | |
| 02 | ការបង់ការប្រាក់ឱ្យទៅអ្នកជាប់ពន្ធ មិនមែនជាស្ថាប័នធនាគារ<br>Payment of interest to non-bank or saving institution taxpayers | | 15% | |
| 03 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំមានកាលកំណត់<br>Payment of interest to taxpayers who have fixed term deposit accounts | | 6% | |
| 04 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំគ្មានកាលកំណត់<br>Payment of interest to taxpayers who have non-fixed term saving | | 4% | |
| 05 | ការបង់ថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ (នីតិបុគ្គល)<br>Payment of rental/lease of movable and immovable property Legal Person | | 10% | |
| 06 | ការបង់ថ្លៃឈ្នួលចលនទ្រព្យ និងអចលនទ្រព្យ (រូបវន្តបុគ្គល)<br>Payment of rental/lease of movable and immovable property Physical Person | | 10% | |
| | សរុប Total | | | |

| ល.រ No. | ពន្ធកាត់ទុកលើអនិវាសនជន Withholding tax on non-resident (A) | ទឹកប្រាក់ត្រូវបើក Amount to be paid (B) | អត្រាពន្ធ Tax rate (C) | ពន្ធកាត់ទុក Withholding tax (D = B x C) |
|---|---|---|---|---|
| 01 | ការបង់ការប្រាក់<br>Payment of interest | | 14% | |
| 02 | ការបង់សួយសារ ថ្លៃឈ្នួល ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ<br>Payment of royalty, rental/leasing, and income related to the use of property | | | |
| 03 | ការទូទាត់ថ្លៃសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា<br>Payment of management fee and technical services | | | |
| 04 | ការបង់ភាគលាភ<br>Payment of dividend | | | |
| 05 | សេវាកម្ម<br>Service | | | |
| | សរុប Total | | | |




# ៥.ពន្ធលើប្រាក់បៀវត្ស

# ១. ប្រាក់បៀវត្ស

**ប្រាក់បៀវត្ស** សំដៅដល់ ÷

- បៀវត្ស - លាភការ
- ប្រាក់បំណាច់ - បុព្វលាភ (Bonus)
- ប្រាក់ម៉ោងបន្ថែម - ប្រាក់ប៉ះប៉ូវនានា

និង អត្ថប្រយោជន៍បន្ថែម

ដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងាររបស់និយោជិត។

# ២.អត្ថប្រយោជន៍បន្ថែម

អត្ថប្រយោជន៍បន្ថែមទាំងនោះជាអាទិ៍មាន៖

ក. យានជំនិះគ្រប់ប្រភេទ

ខ. ម្ហូបអាហារ

គ. លំនៅដ្ឋាន ការស្នាក់នៅ

ឃ. ទឹក ភ្លើង ទូរស័ព្ទ

ង. អ្នកបម្រើការងារក្នុងលំនៅឋាន

ច. ប្រាក់ឱ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ។ អត្រាការប្រាក់ទីផ្សារ ត្រូវកំណត់ដោយក្រសួងស.ហ.វ

# ២.អត្ថប្រយោជន៍បន្ថែម(ត)

ឆ. ការលក់ទំនិញចុះថ្លៃ

ជ. ជំនួយផ្នែកអប់រំសម្រាប់និយោជិត ដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្ដុះបណ្ដាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ

ឈ. ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត

ញ. បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្ដល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ

# ២.អត្ថប្រយោជន៍បន្ថែម(ត)

ង. ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផល និង មិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក

ច. ចំនួនប្រាក់បង់ចូលមូលនិធិសុខុមាលភាពសង្គមដែលលើសពីកម្រិត ដែលច្បាប់បានអនុញ្ញាត

ឆ. ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី១០% នៃប្រាក់បៀវត្ស ប្រចាំខែគ្មានបូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត

ឈ. ចំណាយសម្រាប់ការទទួលភ្ញៀវ ការកម្សាន្ត ការសម្រាកលំហែ ឬការប្រើ ប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះ ដែលមិន មែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ

ញ. ការផ្តល់ឱ្យចំណែកណាមួយនៃភាគហ៊ុន ឬទុនក្រុមហ៊ុន។

# ៣.១.ការគណនាពន្ធលើប្រាក់បៀវត្ស

## ក. ការគណនាពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធនិវាសនជន

| បៀវត្សជារៀល | អត្រា | គណនា |
|---|---|---|
| 0 ដល់ 1,500,000 | 0% | |
| 1,500,001 ដល់ 2,000,000 | 5% | ម x 5% - 75,000 |
| 2,000,001 ដល់ 8,500,000 | 10% | ម x 10% - 175,000 |
| 8,500,001 ដល់ 12,500,000 | 15% | ម x 15% - 600,000 |
| លើសពី 12,500,000 | 20% | ម x 20% - 1,225,000 |

# ៣.២.ការគណនាអត្ថប្រយោជន៍បន្ថែម

- **អត្ថប្រយោជន៍បន្ថែម** រួមមានទំនិញ និងសេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬវត្ថុផ្សេងទៀតដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬប្រយោលដល់រូបវន្តបុគ្គល ចំពោះសកម្មភាពបម្រើការងារ។
- ជារៀងរាល់ខែ និយោជកត្រូវកាត់ទុក និងបង់ប្រាក់ពន្ធ តាមអត្រា **២០%**។
- តម្លៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ ហើយត្រូវជាប់ពន្ធក្នុងខែដែលបានផ្តល់ឱ្យនិយោជិត។

# ៣.៣.ពន្ធលើប្រាក់បៀវត្សអនិវាសនជន

**ការកំណត់ពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធអនិវាសនជន**

សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា **២០ ភាគរយ** លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធ ដោយមិនមានការអនុញ្ញាត ឱ្យដកទាយជូទានសម្រាប់សហព័ទ្ធជាមេផ្ទះ និងកូនក្នុងបន្ទុកទេ។

# ៣.៤. ប្រាក់បៀវត្សលើកលែងពន្ធ

**ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ**

ក. ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយ **ដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ** បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ៣.៤. ប្រាក់បៀវត្សលើកលែងពន្ធ(ត)

ខ. ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស នៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

✍ ការលើកលែងពន្ធក្នុងចំណុចនេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ។

# ៣.៤. ប្រាក់បៀវត្សលើកលែងពន្ធ(ត)

**ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត មានដូចខាងក្រោម÷**

១. ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខខណ្ឌ ៣ ដូចតទៅ÷

*ក. បានចាយក្នុងប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស*

*ខ. មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ*

*គ. បានបង្ហាញជាភស្តុតាងដោយវិក្កយបត្ររាយលម្អិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ។*

# ៣.៤. ប្រាក់បៀវត្សលើកលែងពន្ធ(ត)

២. ប្រាក់បំណាច់នានានៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្ត ក្នុងច្បាប់ការងារ។

៣. លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តក្នុង ច្បាប់ការងារ។

៤. ការផ្គត់ផ្គង់ឱ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវ ឯកសណ្ឋាន ឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស ប្រសិនបើនិយោជិតត្រូវ បង្វិលសម្ភារៈទាំងនោះសងទៅនិយោជកវិញនៅពេលឈប់បម្រើការងារ។

៥. ប្រាក់បំណាច់ម៉ៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ។ ប្រាក់ បំណាច់នេះ មិនត្រូវត្រួតគ្នាជាមួយប្រាក់សំណងពិតប្រាកដ នូវចំណាយដូចមានចែងខាងលើឡើយ។

# ៣.៤. ប្រាក់បៀវត្សលើកលែងពន្ធ(ត)

**នាយដ្ឋានសម្រាប់ និយោជិតនិវាសជន ដែលមាន ÷**

ក. កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានគិតពន្ធចំនួន ១៥០ ០០០ រៀល ក្នុងកូនម្នាក់ៗក្នុងមួយខែ។

ខ. សហព័ទ្ធដែលធ្វើតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានគិតពន្ធចំនួន ១៥០ ០០០ រៀល សម្រាប់តែម្នាក់ក្នុងមួយខែ។

✍ កូនក្នុងបន្ទុក អាយុមិនលើសពី១៨ឆ្នាំ ឬជាសិស្ស ឬនិស្សិតដែលមានអាយុមិនលើសពី២៥ឆ្នាំ

# ប្រាក់ឧបត្ថម្ភដែលមិនជាប់ពន្ធលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ថែម
## សារាចរលេខ ០១១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦

1. សោហ៊ុយធ្វើដំណើរទៅ-មកពីកន្លែងស្នាក់នៅទៅកន្លែងធ្វើការ ឬការផ្តល់កន្លែងស្នាក់នៅក្នុងបរិវេណទីកន្លែងធ្វើការស្របតាមបញ្ញត្តិនៃច្បាប់ការងារ
2. ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិតទាំងអស់គ្មានបែងចែកតួនាទីឬមុខងារ
3. មូលនិធិបេឡាសន្តិសុខសង្គមឬមូលនិធិសុខមាលភាពសង្គមតាមបញ្ញត្តច្បាប់
4. ប្រាក់ធានារ៉ាប់រងសុខភាព ឬបុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព ដែលផ្តល់ឱ្យកម្មករនិយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទីឬមុខងារ
5. ប្រាប់ឧបត្ថម្ភទារក ឬចំណាយទារកដ្ឋាន តាមច្បាប់ការងារ
6. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬប្រាក់បំណាច់បញ្ឈប់លែងឱ្យធ្វើការ ក្នុងកម្រិតដែលបានបញ្ញត្តក្នុងច្បាប់ការងារ

# លិខិតប្រកាសពន្ធលើបៀវត្ស និងអត្ថប្រយោជន៍បន្ថែម

## II.សរុបប្រាក់ពន្ធ / TOTAL AMOUNT OF TAX

| ល.រ No. | ប្រភេទពន្ធ Type of tax | ពន្ធត្រូវបង់ Tax payable |
|---|---|---|
| ០១ | ពន្ធលើប្រាក់បៀវត្ស Tax on Salary | |
| ០២ | ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on Salary on Fringe Benifit | |

## III. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតនិវាសនជន / TAX ON SALARY FOR RESIDENT EMPLOYEES

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់បៀវត្សត្រូវបើក Salary to be paid | សហព័ទ្ធ Spouse | ចំនួនកូនក្នុងបន្ទុក No. of minor children | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|---|---|
| 1 | | | | | 0% | |
| 2 | | | | | 5% | |
| 3 | | | | | 10% | |
| 4 | | | | | 15% | |
| 5 | | | | | 20% | |
| សរុប Total | | | | | | |

## IV. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតអនិវាសនជន / TAX ON SALARY FOR NON-RESIDENT EMPLOYEES

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់បៀវត្សត្រូវបើក Salary to be paid | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្ស Tax on Salary |
|---|---|---|---|---|
| | A | B | C | D = B x C |
| 1 | | | 20% | |

## V. ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម / TAX ON SALARY ON FRINGE BENEFIT

| ល.រ No. | ចំនួននិយោជិត No. of employees | ប្រាក់អត្ថប្រយោជន៍បន្ថែម Fringe benefit | អត្រាពន្ធ Tax rate | ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម Tax on salary on Fringe benefit |
|---|---|---|---|---|
| | A | B | C | D = B x C |
| 1 | | | 20% | |

# ៥. ភាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត

**កាព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ៖**

(ប្រការ១០ នៃប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨)

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវដាក់លិខិតប្រកាសពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់៖

I. កាតព្វកិច្ចបង់ពន្ធប្រចាំខែ (យឺតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ចំពោះការដាក់លិខិតប្រកាសដោយផ្ទាល់ ឬត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់ចំពោះការដាក់លិខិតប្រកាសអនឡាញ E-Filing)
   1. ពន្ធលើប្រាក់បៀវត្ស
   2. ពន្ធកាត់ទុក
   3. អាករលើតម្លៃបន្ថែម (ករណីអង្គការធ្វើសកម្មភាពអាជីវកម្មដោយឡែក)
   4. ពន្ធអាករផ្សេងៗ

II. កាតព្វកិច្ចសារពើពន្ធប្រចាំឆ្នាំ (យឺតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់)
   1. ពន្ធប៉ាតង់ (ករណីអង្គការធ្វើសកម្មភាពអាជីវកម្មដោយឡែក)
   2. ពន្ធលើប្រាក់ចំណូល (ករណីអង្គការធ្វើសកម្មភាពអាជីវកម្មដោយឡែក)

# ៥. កាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត

**កាតព្វកិច្ចក្នុងការកាន់កាប់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុ**

- សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលត្រូវកាន់កាប់ កត់ត្រានិងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុនានា ឬទិនានុប្បវត្តិដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជី ឬឯកសារទាំងនោះ ក្នុងរយៈពេល១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធ។




ចំណូលពន្ធដារសម្រាប់

- បើកប្រាក់ខែជូនមន្ត្រីរាជការ
- សាងសង់មន្ទីរពេទ្យ
- សាងសង់សាលារៀន
- សាងសង់ថ្នល់






ចំណូលពន្ធដារសម្រាប់

- ការពារព្រំដែន
- ចំណាយទូទៅ សង្គមកិច្ច សេដ្ឋកិច្ច និងការអភិវឌ្ឍន៍
- បើកប្រាក់ខែជូនកងទ័ព និងកម្លាំងប្រដាប់អាវុធ
- សាងសង់ស្ពាន











បើកប្រាក់ខែជូនមន្ត្រីរាជការ
To Pay Salary For Civil Servants
សាងសង់មន្ទីរពេទ្យ
To Build Hospitals
បើកប្រាក់ខែជូនទាហានកម្លាំងប្រដាប់អាវុធ
To Pay Salary For Soldiers And Forces
សាងសង់ផ្លូវ
To Build Roads
TAXES
សាងសង់ស្ពាន
To Build Bridges
ការពារព្រំដែន
To Defend Borders & Heritages
សាងសង់សាលារៀន
To Build Schools




9:45
1277
calling...
mute
keypad
speaker
add call
FaceTime
ទូរស័ព្ទមកលេខ
១២៧៧
ដោយឥតគិតថ្លៃ
រួចចុចលេខ ១ ▶ ២

# សូមអរគុណ!